# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៤៥...សសរ...

## សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការ

## ទិវាសប្ដាហ៍វប្បធម៌អាស៊ានលើកទី១ ឆ្នាំ ២០០២

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការរៀបចំទិវាសប្ដាហ៍វប្បធម៌អាស៊ានលើកទីមួយ ដែលមានសមាសភាពដូចខាងក្រោម :

១-សម្ដេចព្រះរាម **នរោត្តម បុប្ផាទេវី** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រះប្រធាន

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ជាណារ៉ា ស៊ីរីវុឌ្ឍ** រដ្ឋលេខាធិការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ អនុប្រធាន

៣-ឯកឧត្ដម **ប៉ែន យ៉ែត** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន

៤-ឯកឧត្ដម **សេខ លឹមនៅ** អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៥-ឯកឧត្ដម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា សមាជិក

៦-ឯកឧត្ដម **ទី តាឃី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៧-ឯកឧត្តម **ម៉ប់ សារិន** អភិបាលរងរាជធានីភ្នំពេញ សមាជិក
៨-ឯកឧត្តម **ចាន់ សុផល** អភិបាលរងខេត្តសៀមរាប សមាជិក
៩-ឯកឧត្តម **សាម្ងួន ជន** អនុរដ្ឋលេខាធិការក្រសួងពត៌មាន សមាជិក
១០-ឯកឧត្តម **ជុំ ភឿន** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១១-ឯកឧត្តម **ពេជ្រ ឆុំក្រចិល** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១២-ឯកឧត្តម **គឹម សុផារត** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១៣-ឯកឧត្តម **មីសែល ត្រាណ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១៤-ឯកឧត្តម **អ៊ុក សុជាតិ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១៥-ឯកឧត្តម **ទូ គឹមឈៀ** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១៦-ឯកឧត្តម **ឆា សុត្ថា** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
១៧-ឯកឧត្តម **វស់ អ៊ីន** អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
១៨-ឯកឧត្តម **ម៉ៅ អាយុទ្ធ** អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា សមាជិក
១៩-ឯកឧត្តម **មាស គឹមហេង** អគ្គនាយកក្រសួងការបរទេស សមាជិក
២០-ឯកឧត្តម **តេង សាវង្ស** អគ្គនាយករងអគ្គស្នងការនគរបាលជាតិ សមាជិក
២១-ឯកឧត្តម **ឃឹម សារិទ្ធ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក
២២-ឯកឧត្តម **នុយ គឿន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក
២៣-ឯកឧត្តម **ស៊ឹម សារ៉ាក់** អគ្គនាយករដ្ឋបាលក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
២៤-ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងគណៈកម្មការអចិន្ត្រៃយ៍រៀបចំ
បុណ្យជាតិ និងអន្តរជាតិ សមាជិក
២៥-ឯកឧត្តម **ហង្ស សុត** អគ្គនាយកបច្ចេកទេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
និងជាប្រធានអនុគណៈកម្មាធិការវប្បធម៌អាស៊ាន សមាជិកអចិន្ត្រៃយ៍
២៦-លោក **ឡាយ ប្ញទ្ធី** នាយករងទីចាត់ការគយនិងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច
និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ច :

-កំណត់ទីតាំង ប្រធានបទ រូបភាពខ្លឹមសារ
-រៀបចំទទួលភ្ញៀវជាតិ និងអន្តរជាតិ
-រៀបចំសន្តិសុខនិងសណ្តាប់ធ្នាប់
-សំរួលបែបបទចេញចូលផ្នែកទិដ្ឋាការ និងផ្នែកគយ
-សំរួលដល់ការធ្វើដំណើរ
-សំរួលការចំណាយក្នុងការរៀបចំទិវាសប្តាហ៍វប្បធម៌អាស៊ាន
-បង្កើតអនុគណៈកម្មការមួយចំនួន បើមានការចាំបាច់

-បង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ មានទីស្នាក់ការពីរ : មួយនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងមួយទៀតនៅអភិរក្សដ្ឋានអង្គរ ( សៀមរាប )

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រាមូលរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គណៈកម្មការបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង ព្រមទាំងសាមីជន ដែលមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ

-ដូចប្រការ ៤

-ឯកសារ-កាលប្បវត្តិ